ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**អន្តរក្រសួង**
ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ក្រសួងការពារជាតិ
ក្រសួងមហាផ្ទៃ
លេខ ០២១ ស.អ.យ.

# សារាចរណែនាំអន្តរក្រសួង
# ស្តីពី
# ការត្រួតពិនិត្យ ផ្ទៀងផ្ទាត់អតីតយុទ្ធជនគ្រប់ប្រភេទ និងគ្រួសារ

ដើម្បីសម្តែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅ និងការយកចិត្តទុកដាក់ខ្ពស់របស់រាជរដ្ឋាភិបាលកម្ពុជា ចំពោះអតីតយុទ្ធជន និងគ្រួសារ ដែលបានធ្វើពលីកម្មដ៏ថ្លៃថ្លា ដើម្បីបុព្វហេតុជាតិ និងប្រជាពលរដ្ឋកម្ពុជា។

អនុវត្តតាមលិខិតលេខ ៨០៤ សជណ ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០០៦ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីសំណើសុំគោលការណ៍ និងវិធានការមួយចំនួនលើវិស័យអតីតយុទ្ធជន ឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ និងទទួលបានលទ្ធផលល្អប្រសើរ អន្តរក្រសួងរួមមាន : ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងការពារជាតិ និងក្រសួងមហាផ្ទៃ ធ្វើការណែនាំដូចតទៅ :

## I- ការកសាងសំណុំលិខិត ឯកសារ អតីតយុទ្ធជនគ្រប់ប្រភេទ និងគ្រួសារ និងការផ្ទេរ_ទទួល

ការបំពេញសំណុំលិខិតនិងការផ្ទេរ-ទទួលអតីតយុទ្ធជន និងគ្រួសារ នៅតែបន្តអនុវត្តតាមគោលការណ៍រួម ដែលបានកំណត់កន្លងមកដូចតទៅ :

**១-រវាងក្រសួងការពារជាតិ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

**ក-**និវត្តជន និងជនបាត់បង់សមត្ថភាពការងារ អនុវត្តតាមការកំណត់របស់ប្រកាសអន្តរក្រសួងលេខ ១២៩ / ២០០៧ ប្រក អន ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០០៧ របស់ក្រសួងការពារជាតិ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្តីពីការកំណត់អំពីបែបបទផ្ទេរប្រគល់ ការគ្រប់គ្រង ចំពោះនិវត្តជន និងជនបាត់បង់សមត្ថភាពការងារ ។

**ខ-**ជនពិការ គ្រួសារជនពលី និងគ្រួសារជនមរណៈ អនុវត្តតាមការកំណត់ របស់សារាចរណែនាំអន្តរក្រសួងលេខ ០០១ សរណ អក ២០០៧ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០០៧ របស់ក្រសួងការពារជាតិ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងសុខាភិបាល និង ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្តីពីការអនុវត្តន៍អនុក្រឹត្យលេខ ០៨ អនក្រ.បក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០០៧ ស្តីពីរបបឧបត្ថម្ភចំពោះយោធិនពលី មរណៈ បង្គូស្លាប់ បាត់ខ្លួន និងពិការ ។

**២-រវាងក្រសួងមហាផ្ទៃ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

**ក-**និវត្តជន និងជនបាត់បង់សមត្ថភាពការងារ អនុវត្តតាមការកំណត់របស់ប្រកាសអន្តរក្រសួងលេខ ១៨៧៧ ប្រក ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១០ របស់ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្តីពីការកំណត់អំពីបែបបទផ្ទេរ ប្រគល់ ការគ្រប់គ្រងនិវត្តជន និងជនបាត់បង់សមត្ថភាពការងារ ។

ខ-ជនពិការ គ្រួសារជនពលី និងគ្រួសារជនមរណៈ អនុវត្តតាមការកំណត់របស់សារាចរណែនាំអន្តរក្រសួង ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងសុខាភិបាល និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្តីពីការអនុវត្តន៍អនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០០៩ ស្តីពីរបបឧបត្ថម្ភគោលនយោបាយ ចំពោះមន្ត្រីនគរបាលពលី មរណៈ បង្គុស្លាប់ បាត់ខ្លួន និងពិការ ។

គ-ជនពិការ គ្រួសារជនពលី ជាអតីតមន្ត្រីរាជការស៊ីវិល កងជីវពល កងសេនាជន ប្រជាពលរដ្ឋ និងគ្រួសារ អនុវត្តតាមការកំណត់របស់សារាចរណែនាំអន្តរក្រសួងលេខ០៤ សកអ ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ១៩៩៤ របស់ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន ក្រសួងសុខាភិបាល ក្រសួងការពារជាតិ និងក្រសួងមហាផ្ទៃ ស្តីពីរបៀបបំពេញសំណុំលិខិត និងសម្រេចទទួលស្គាល់ជនពលី ពិការ ។

**៣-ការផ្ទេរ-ទទួលអតីតយុទ្ធជនគ្រប់ប្រភេទ និងគ្រួសារ និងការដោះស្រាយប្រាក់ឧបត្ថម្ភ**

ក-ការត្រួតពិនិត្យលើសំណុំលិខិត ឯកសារ :

ក្រសួងការពារជាតិ ក្រសួងមហាផ្ទៃ និងក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវរៀបចំសំណុំលិខិតឯកសារ របស់អតីតយុទ្ធជនគ្រប់ប្រភេទ និងគ្រួសារ ឱ្យបានត្រឹមត្រូវតាមគោលការណ៍ និងត្រូវទុករយៈពេល៣ខែ មុនកំណត់ការផ្ទេរ-ទទួល ដើម្បីអនុគណៈកម្មការត្រួតពិនិត្យសំណុំលិខិត ឯកសារ ធ្វើការពិនិត្យផ្ទៀងផ្ទាត់ឱ្យបានត្រឹមត្រូវជាមុន។ សំណុំលិខិត ឯកសារ ដែលកោសលុបឬមិនច្បាស់លាស់ ត្រូវពិនិត្យកែសម្រួលឱ្យបានត្រឹមត្រូវឡើងវិញ ។

លិខិតផ្ទេរ និងបញ្ជីរាយនាមអតីតយុទ្ធជនគ្រប់ប្រភេទ និងគ្រួសារ ត្រូវធ្វើការកែសម្រួល និងបំពេញបន្ថែម ដោយក្រសួងការពារជាតិ ក្រសួងមហាផ្ទៃ ឬក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវថតចម្លងជា ២ច្បាប់ បែងចែកតាមរាជធានីខេត្តនីមួយៗដាច់ពីគ្នា ស្របតាមទីលំនៅដែលអតីតយុទ្ធជន និងគ្រួសាររស់នៅ។ លិខិតផ្ទេរ និងបញ្ជីរាយនាមថតចម្លង ត្រូវចុះហត្ថលេខាដោយប្រធាននាយកដ្ឋានជំនាញនៃក្រសួងការពារជាតិ ក្រសួងមហាផ្ទៃ ឬក្រសួងស្ថាប័នពាក់ព័ន្ធ ។

ខ-ការផ្ទេរ-ទទួល និងការដោះស្រាយប្រាក់ឧបត្ថម្ភ :

ការផ្ទេរ-ទទួលសំណុំលិខិតឯកសារអតីតយុទ្ធជន និងគ្រួសារ ត្រូវបានអនុវត្តតាមគោលការណ៍រួម និងស្របតាមលទ្ធភាពជាក់ស្តែងនៃកញ្ចប់ចំណាយថវិកាប្រចាំឆ្នាំ ដែលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានកំណត់ ។

ការផ្ទេរ-ទទួលអតីតយុទ្ធជន និងគ្រួសារ ត្រូវបានអនុវត្តចំពោះតែអតីតយុទ្ធជន និងគ្រួសារ ដែលមានឈ្មោះ មានមនុស្សពិតប្រាកដ មានអាស័យដ្ឋានច្បាស់លាស់ មានប្រកាសបុគ្គល មានសៀវភៅ ឬប័ណ្ណគ្រួសារ និងអត្តសញ្ញាណប័ណ្ណប្រជាពលរដ្ឋ ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានភារកិច្ចផ្តល់ថវិកាឱ្យបានទាន់ពេលវេលា តាមគោលការណ៍កំណត់ ដើម្បីបន្តនិរន្តរភាពប្រាក់ឧបត្ថម្ភគោលនយោបាយ របស់អតីតយុទ្ធជន និងគ្រួសារ ក្រោយពីក្រសួងការពារជាតិ ក្រសួងមហាផ្ទៃ និងក្រសួងស្ថាប័នពាក់ព័ន្ធ បានកាត់ផ្តាច់ប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗ ផ្ទេរជូនក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ។

គ-អំពីការដោះស្រាយប្រាក់ឧបត្ថម្ភ១លើកដំបូង :

ក្រសួងការពារជាតិ ក្រសួងមហាផ្ទៃ និងក្រសួងស្ថាប័នពាក់ព័ន្ធ ក្នុងការដោះស្រាយប្រាក់ឧបត្ថម្ភ១លើកដំបូង ជូននិវត្តជន ជនបាត់បង់សមត្ថភាពការងារ គ្រួសារជនពលី គ្រួសារជនមរណៈ និងប្រាក់ឧបត្ថម្ភអតីតភាពការងាររបស់ជនពិការ មុនពេលផ្ទេរទៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវអនុវត្តតាមអនុក្រឹត្យលេខ ១០១ អនក្រ.បក ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១០ របស់រាជរដ្ឋាភិបាលស្តីពីការកែសម្រួលការកំណត់របបឧបត្ថម្ភ និងរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ជូនកងយោធពលខេមរភូមិន្ទ និងកងកម្លាំងនគរបាលជាតិ ដែលចូលនិវត្តន៍ បាត់បង់សមត្ថភាពការងារ ពលី មរណៈ បង្គុស្លាប់ បាត់ខ្លួន និងពិការ ។

**II-ការបង្កើតគណៈកម្មការអន្តរក្រសួងត្រួតពិនិត្យផ្ទៀងផ្ទាត់អតីតយុទ្ធជនគ្រប់ប្រភេទ និងគ្រួសារ និងតួនាទីភារកិច្ច**

ដើម្បីធានាប្រសិទ្ធភាព និងតម្លាភាព ក្នុងការងារផ្ទេរ-ទទួលអតីតយុទ្ធជនគ្រប់ប្រភេទ និងគ្រួសារ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល អន្តរក្រសួងសម្រេចបង្កើត គណៈកម្មការត្រួតពិនិត្យផ្ទៀងផ្ទាត់អតីតយុទ្ធជន និងគ្រួសារ អនុគណៈកម្មការត្រួតពិនិត្យសំណុំលិខិត ឯកសារអតីតយុទ្ធជន និងគ្រួសារ និងគណៈកម្មការត្រួតពិនិត្យផ្ទៀងផ្ទាត់ អតីតយុទ្ធជនគ្រប់ប្រភេទ និងគ្រួសារ ថ្នាក់រាជធានី ខេត្ត ដែលមានសមាសភាពដូចតទៅ :



ភ.

**១-គណៈកម្មការអន្តរក្រសួង**

ក-សមាសភាព

១-រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ជាប្រធាន

២-រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ១រូប ជាអនុប្រធាន

៣-រដ្ឋលេខាធិការក្រសួងការពារជាតិ ១រូប ជាអនុប្រធាន

៤-រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ១រូប ជាអនុប្រធាន

៥-រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ១រូប ជាអនុប្រធាន

៦-តំណាងនាយកដ្ឋានសោធននិវត្តន៍ នៃក្រសួងការពារជាតិ ១រូប ជាសមាជិក

៧-តំណាងនាយកដ្ឋានកិច្ចការយោធា-ស៊ីវិលនៃក្រសួងការពារជាតិ ១រូប ជាសមាជិក

៨-តំណាងនាយកដ្ឋានបុគ្គលិកនៃអគ្គស្នងការដ្ឋាននគរបាលជាតិក្រសួងមហាផ្ទៃ ១រូប ជាសមាជិក

៩-តំណាងនាយកដ្ឋានបុគ្គលិកនិងបណ្តុះបណ្តាលវិជ្ជាជីវៈនៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋានក្រសួងមហាផ្ទៃ ១រូប ជាសមាជិក

១០-តំណាងនាយកដ្ឋានថវិកា នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ១រូប ជាសមាជិក

១១- តំណាងនាយកដ្ឋានហិរញ្ញកិច្ច នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ១រូប ជាសមាជិក

១២-នាយកដ្ឋានសោធនអតីតយុទ្ធជន នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ជាលេខាធិការអចិន្ត្រៃយ៍ ។

ខ-តួនាទី ភារកិច្ច

-កំណត់គោលការណ៍ និងវិធានការជាក់ស្តែង ក្នុងការត្រួតពិនិត្យផ្ទៀងផ្ទាត់ អតីតយុទ្ធជនគ្រប់ប្រភេទ និងគ្រួសារ ដែលក្រសួងការពារជាតិ ក្រសួងមហាផ្ទៃ ឬក្រសួងស្ថាប័នពាក់ព័ន្ធ ផ្ទេរជូនក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

-ចេញប្រកាសទទួលស្គាល់ និងផ្តល់ប្រាក់ឧបត្ថម្ភ ជូនអតីតយុទ្ធជន និងគ្រួសារ ដែលត្រូវទទួលតាមរបបកំណត់

-ចេញប្រកាសលុបឈ្មោះអតីតយុទ្ធជន និងគ្រួសារ ដែលមានលក្ខណៈសម្បត្តិផ្ទុយពីគោលការណ៍កំណត់

-ត្រូវកំណត់របបប្រជុំឱ្យបានទៀងទាត់ ដើម្បីដោះស្រាយរាល់បាតុភាព ដែលកើតមានឡើងក្នុងការងារត្រួតពិនិត្យ ការដោះស្រាយប្រាក់ឧបត្ថម្ភ និងបញ្ហាផ្សេងៗទៀត របស់អតីតយុទ្ធជន និងគ្រួសារ ។

**២-អនុគណៈកម្មការត្រួតពិនិត្យសំណុំលិខិត ឯកសារ អតីតយុទ្ធជនគ្រប់ប្រភេទ និងគ្រួសារ**

ក-សមាសភាព អនុគណៈកម្មការត្រួតពិនិត្យសំណុំលិខិត ឯកសារ របស់អតីតយោធិន នៃកងយោធពលខេមរភូមិន្ទ

១-នាយកដ្ឋានសោធនអតីតយុទ្ធជន នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ជាប្រធាន

២-តំណាងនាយកដ្ឋានកិច្ចការយោធា-ស៊ីវិលនៃក្រសួងការពារជាតិ ១រូប ជាអនុប្រធាន

៣-តំណាងនាយកដ្ឋានសោធននិវត្តន៍ នៃក្រសួងការពារជាតិ ១រូប ជាអនុប្រធាន

៤- តំណាងនាយកដ្ឋានថវិកា នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ១រូប ជាអនុប្រធាន

៥- តំណាងនាយកដ្ឋានហិរញ្ញកិច្ច នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ១រូប ជាអនុប្រធាន

ខ-សមាសភាព អនុគណៈកម្មការត្រួតពិនិត្យសំណុំលិខិត ឯកសារ របស់អតីតមន្ត្រីនគរបាលជាតិ កងសេនាជន កងជីវពល និងប្រជាពលរដ្ឋ

១-នាយកដ្ឋានសោធនអតីតយុទ្ធជន នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ជាប្រធាន

២-តំណាងនាយកដ្ឋានបុគ្គលិកអគ្គស្នងការដ្ឋាននគរបាលជាតិ នៃក្រសួងមហាផ្ទៃ ១រូប ជាអនុប្រធាន

៣-តំណាងនាយកដ្ឋានបុគ្គលិកនិងបណ្តុះបណ្តាលវិជ្ជាជីវៈនៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋានក្រសួងមហាផ្ទៃ ១រូប ជាអនុប្រធាន

៤- តំណាងនាយកដ្ឋានថវិកា នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ១រូប ជាអនុប្រធាន

៥- តំណាងនាយកដ្ឋានហិរញ្ញកិច្ច នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ១រូប ជាអនុប្រធាន

៦- និងមានសមាសភាពមួយចំនួនទៀត ជាសមាជិក

គ-តួនាទី ភារកិច្ច របស់អនុគណៈកម្មការទាំង ២

-ធ្វើជាសេនាធិការ ជូនគណៈកម្មការអន្តរក្រសួង

-ផ្ទៀងផ្ទាត់សំណុំលិខិត ឯកសារ អតីតយុទ្ធជនគ្រប់ប្រភេទ និងគ្រួសារ ឱ្យបានត្រឹមត្រូវតាមគោលការណ៍ ក្នុងរយៈពេល០៣ខែ មុនកាលកំណត់ផ្ទេរ-ទទួលអតីតយុទ្ធជនៈ និងគ្រួសារ រវាងក្រសួងការពារជាតិ ក្រសួងមហាផ្ទៃ ឬក្រសួងស្ថាប័នពាក់ព័ន្ធ ជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

-បំពេញបែបបទ និងលើកសំណើជូន ប្រធានគណៈកម្មការអន្តរក្រសួង ចេញប្រកាសទទួលស្គាល់ និងផ្តល់ប្រាក់ឧបត្ថម្ភប្រចាំខែ ជូនអតីតយុទ្ធជនគ្រប់ប្រភេទ និងគ្រួសារ ឬលើកសំណើសុំលុបឈ្មោះអតីតយុទ្ធជន និងគ្រួសារ ដែលមានលក្ខណៈសម្បត្តិផ្ទុយពីគោលការណ៍កំណត់ ។

-បូកសរុបលទ្ធផលការងារ ដែលក្រុមការងាររាជធានី ខេត្តបានអនុវត្ត និងធ្វើរបាយការណ៍ ជូនថ្នាក់ដឹកនាំអន្តរក្រសួងបានជ្រាប និងមានវិធានការអនុវត្តជាក់ស្តែង និងទាន់ពេលវេលា ។

សមាសភាពគណៈកម្មការអន្តរក្រសួង និងអនុគណៈកម្មការត្រួតពិនិត្យសំណុំលិខិត ឯកសារ ត្រូវបានបង្កើតឡើងដោយប្រកាស របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងប្រើប្រាស់ត្រារបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ជាផ្លូវការ ។

**៣-គណៈកម្មការត្រួតពិនិត្យផ្ទៀងផ្ទាត់ អតីតយុទ្ធជនគ្រប់ប្រភេទ និងគ្រួសារ ថ្នាក់រាជធានី ខេត្ត**

**ក**-សមាសភាព

| | |
|---|---|
| ១-អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត | ជាប្រធាន |
| ២-ប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត | ជាអនុប្រធានអចិន្ត្រៃយ៍ |
| ៣-មេបញ្ជាការ ឬមេបញ្ជាការរង នៃតំបន់ប្រតិបត្តិការសឹករងរាជធានី ខេត្ត | ជាអនុប្រធាន |
| ៤-ស្នងការ ឬស្នងការរងនៃស្នងការដ្ឋាននគរបាលរាជធានី ខេត្ត | ជាអនុប្រធាន |
| ៥-ប្រធាន ឬអនុប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត | ជាអនុប្រធាន |
| ៦-អភិបាល ឬអភិបាលរងនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ | ជាសមាជិក |
| ៧-ជំនួយការផ្នែកការងារពលី មរណៈ និងពិការ នៃតំបន់ប្រតិបត្តិការសឹករងរាជធានី ខេត្ត | ជាសមាជិក |
| ៨-ជំនួយការផ្នែកសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារនៃតំបន់ប្រតិបត្តិការសឹករងរាជធានី ខេត្ត | ជាសមាជិក |
| ៩-នាយ ឬនាយរងការិយាល័យបុគ្គលិក នៃស្នងការដ្ឋាននគរបាលរាជធានី ខេត្ត | ជាសមាជិក |
| ១០-ប្រធាន ឬអនុប្រធានការិយាល័យថវិកា នៃមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត | ជាសមាជិក |
| ១១-មេឃុំ ចៅសង្កាត់ | ជាសមាជិក |
| ១២-ការិយាល័យអតីតយុទ្ធជននៃមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត | ជាសមាជិក |
| ១៣-ការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រុង ស្រុក ខណ្ឌ | ជាសមាជិក |

សមាសភាព គណៈកម្មការត្រួតពិនិត្យផ្ទៀងផ្ទាត់ អតីតយុទ្ធជនគ្រប់ប្រភេទ និងគ្រួសារថ្នាក់រាជធានី ខេត្ត ត្រូវបានបង្កើតឡើងដោយដីការរបស់គណៈអភិបាលរាជធានី ខេត្ត ក្រោយពីទទួលបានការឯកភាព ពីក្រុមប្រឹក្សាថ្នាក់រាជធានី ខេត្ត និងប្រើប្រាស់ត្រារដ្ឋបាលរបស់សាលារាជធានីខេត្ត ជាផ្លូវការ។ ក្នុងករណីប្រធានគណៈកម្មការ ផ្ទេរសិទ្ធិជូនអនុប្រធានអចិន្ត្រៃយ៍ ត្រូវប្រើប្រាស់ត្រាមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ជាផ្លូវការ ។

**ខ**-តួនាទី ភារកិច្ច

-ត្រួតពិនិត្យ ផ្ទៀងផ្ទាត់បញ្ជីឈ្មោះអតីតយុទ្ធជន គ្រប់ប្រភេទ និងគ្រួសារ របស់ក្រសួងស្ថាប័នដើម ជាមួយអតីតយុទ្ធជន និងគ្រួសារផ្ទាល់ នៅតាមលំនៅឋាន ក្រុម ភូមិ ឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ ដែលអតីតយុទ្ធជន និងគ្រួសាររស់នៅ ។

-ត្រួតពិនិត្យផ្ទៀងផ្ទាត់វត្តមានពិតប្រាកដ របស់ក្រុមគ្រួសារ ដែលមាន :

វត្តមានប្រពន្ធ ឬប្តី ឪពុក ម្តាយបង្កើត ឬអ្នកអាណាព្យាបាល ( មានប្តី ឬប្រពន្ធថ្មីទៀត នៅរស់ ឬស្លាប់ )



ភ.

វត្តមានជាក់ស្តែងរបស់កូនបង្កើត នាមត្រកូល និងនាមខ្លួន ថ្ងៃខែឆ្នាំកំណើត មុខរបរ ។ កូនមានអាយុលើសពី១៥ឆ្នាំ ឬ១៨ឆ្នាំ កំពុងសិក្សា ឬមិនសិក្សា ។ បើកំពុងសិក្សា ត្រូវមានលិខិតបញ្ជាក់ពីនាយកសាលា ដែលកូនទាំងនោះកំពុងសិក្សា ។

-អតីតយុទ្ធជនគ្រប់ប្រភេទ និងគ្រួសារ ដែលក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានចេញប្រកាសទទួលស្គាល់ ត្រូវបានបញ្ជូនទៅដល់រាជធានី ខេត្ត មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត ត្រូវគ្រោងថវិកាស្នើសុំទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាបន្ទាន់ ជៀសវាងភាពយឺតយ៉ាវក្នុងការបើកប្រាក់ឧបត្ថម្ភប្រចាំខែ ធ្វើឱ្យប៉ះពាល់ដល់ជីវភាពអតីតយុទ្ធជន និងគ្រួសារ និងនាំឱ្យមានប្រាក់រំលឹកគរច្រើន។ នៅពេលទទួលបានថវិកា មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវធ្វើសេចក្តីជូនដំណឹងមកក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងគណៈកម្មការត្រួតពិនិត្យផ្ទៀងផ្ទាត់រាជធានី ខេត្ត ចូលរួមត្រួតពិនិត្យបើកផ្តល់ និងត្រូវធ្វើសេចក្តីជូនដំណឹង ដល់អតីតយុទ្ធជន និងគ្រួសារ ដែលត្រូវទទួលប្រាក់ឧបត្ថម្ភ ដោយកំណត់កន្លែង និងថ្ងៃខែឆ្នាំបើកប្រាក់ច្បាស់លាស់ ។ ការត្រួតពិនិត្យផ្ទៀងផ្ទាត់អតីតយុទ្ធជន និងគ្រួសារ ត្រូវអនុវត្តជាមួយការបើកប្រាក់ឧបត្ថម្ភប្រចាំខែ ស្របតាមវិធានការដែលបានលើកឡើងខាងលើ និងវិធានការអនុវត្ត ដែលបានកំណត់ក្នុងចំណុចទី III ។

-អតីតយុទ្ធជន និងគ្រួសារ ដែលមានធុរៈធ្ងន់ធ្ងរមិនអាចមកបើកប្រាក់ឧបត្ថម្ភបាន ត្រូវបានផ្ទេរសិទ្ធិជូនគ្រួសារ។ លិខិតផ្ទេរសិទ្ធិត្រូវបញ្ជាក់ពីមូលហេតុច្បាស់លាស់ និងមានការបញ្ជាក់ពីអាជ្ញាធរឃុំ សង្កាត់ ឬអង្គភាពគ្រប់គ្រងផ្ទាល់ ។

-ត្រូវលើកសំណើជូន ប្រធានគណៈកម្មការអន្តរក្រសួង ដើម្បីទទួលស្គាល់ និងផ្តល់ប្រាក់ឧបត្ថម្ភ ជូនអតីតយុទ្ធជន និងគ្រួសារដែលមានលក្ខណៈសម្បត្តិ ស្របតាមគោលការណ៍កំណត់ ឬលុបឈ្មោះអតីតយុទ្ធជន និងគ្រួសារ ដែលមានលក្ខណៈសម្បត្តិ ផ្ទុយពីគោលការណ៍ មានតែឈ្មោះ មិនមានមនុស្សពិតប្រាកដ និងដែលផុតសុពលភាពទទួលប្រាក់ឧបត្ថម្ភ។ សំណើ និងបញ្ជីរាយនាមអតីតយុទ្ធជន គ្រប់ប្រភេទ និងគ្រួសារ ត្រូវបានរៀបចំតាមលំដាប់ តាមសំណើរបស់ក្រសួងស្ថាប័នដើម តាមលេខរៀង លេខប្រកាសរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ។

-បើការត្រួតពិនិត្យផ្ទៀងផ្ទាត់អតីតយុទ្ធជនគ្រប់ប្រភេទ និងគ្រួសារ ជួបការលំបាកស្មុគ្រស្មាញ ឬមានឧបសគ្គ បង្កឱ្យមានការរាំងស្ទះដល់កិច្ចដំណើរការ ត្រូវធ្វើសេចក្តីរាយការណ៍ជាបន្ទាន់ ជូនគណៈកម្មការអន្តរក្រសួង ដើម្បីមានវិធានការដោះស្រាយ ។

**III – វិធានការអនុវត្ត**

**១**-ការពិនិត្យ និងកំណត់ប្រាក់ឧបត្ថម្ភ ជូនអតីតយុទ្ធជនគ្រប់ប្រភេទ និងគ្រួសារ ត្រូវធ្វើការផ្ទៀងផ្ទាត់ រវាងលិខិតទទួលស្គាល់ ប្រវត្តិរូបសង្ខេប និងលិខិតផ្តត់ផ្គង់ហិរញ្ញវត្ថុ។ ករណីស្ថានភាពគ្រួសារមានលក្ខណៈខុសគ្នា ត្រូវយកលិខិតផ្តត់ផ្គង់ហិរញ្ញវត្ថុ ធ្វើជាមូលដ្ឋានក្នុងការកំណត់ប្រាក់ឧបត្ថម្ភ ។ នៅពេលធ្វើការត្រួតពិនិត្យជាក់ស្តែង មានកូន ប្រពន្ធ ឬប្តី ឪពុក ម្តាយបង្កើត ឬអ្នកអាណាព្យាបាល មានចំនួនខុសពីការកំណត់ក្នុងលិខិតទទួលស្គាល់ ប្រវត្តិរូបសង្ខេប និងលិខិតផ្តត់ផ្គង់ហិរញ្ញវត្ថុ របស់ក្រសួងស្ថាប័នដើម ឬប្រកាសទទួលស្គាល់ និងផ្តល់ប្រាក់ឧបត្ថម្ភគោលនយោបាយ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវកំណត់យកតាមសៀវភៅ ឬ ប័ណ្ណគ្រួសារ អត្តសញ្ញាណប័ណ្ណប្រជាពលរដ្ឋ និងត្រូវលើកសំណើជូនប្រធានគណៈកម្មការអន្តរក្រសួងទទួលស្គាល់ និងផ្តល់របបឧបត្ថម្ភបន្ថែម ឬក៏ត្រូវលុបឈ្មោះចេញពីបញ្ជីបើកប្រាក់ឧបត្ថម្ភ តាមគោលការណ៍កំណត់។

**២**-ការត្រួតពិនិត្យផ្ទៀងផ្ទាត់ ត្រូវបានធ្វើដោយការគូបផ្សំរវាងសំណុំលិខិត ប្រកាសរួម និងបុគ្គលរបស់ក្រសួងស្ថាប័នដើម ជាមួយសៀវភៅ ឬប័ណ្ណគ្រួសារ អត្តសញ្ញាណប័ណ្ណប្រជាពលរដ្ឋ ឬឯកសារដែលមានការពាក់ព័ន្ធ។ ករណីគ្រួសារអតីតយុទ្ធជនពិតប្រាកដ ដែលមានឈ្មោះខុសពីបញ្ជីឈ្មោះរបស់ក្រសួងស្ថាប័នដើម ត្រូវយកតាមសៀវភៅ ប័ណ្ណគ្រួសារ អត្តសញ្ញាណប័ណ្ណប្រជាពលរដ្ឋ។ ចំពោះឈ្មោះអតីតយុទ្ធជនផ្ទាល់ ត្រូវរក្សាទុកតាមបញ្ជីឈ្មោះ រេរបស់ក្រសួងស្ថាប័នដើមដដែល ។

**៣**-អតីតយុទ្ធជន ឬគ្រួសារ ដែលរកមិនឃើញតាមអាស័យដ្ឋានកំណត់ ត្រូវព្យួរឈ្មោះទុកបន្តត្រួតពិនិត្យក្នុងរយៈពេល ០៣ ខែ ទៅមុខទៀត ។ ក្នុងរយៈពេលនេះ ត្រូវធ្វើសេចក្តីរាយការណ៍ អំពីលទ្ធផលនៃការត្រួតពិនិត្យអតីតយុទ្ធជន គ្រប់ប្រភេទនិងគ្រួសារ មកក្រសួងការពារជាតិ ក្រសួងមហាផ្ទៃ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ឬក្រសួងស្ថាប័នពាក់ព័ន្ធ ដើម្បីសហការជាមួយអាជ្ញាធរ ឃុំ សង្កាត់ ក្នុងការស្រាវជ្រាវស្វែងរក និងត្រូវបន្តធ្វើសេចក្តីជូនដំណឹងជាប្រចាំ ដល់អតីតយុទ្ធជន និងគ្រួសារ ។ ផុតរយៈពេលកំណត់ ត្រូវលើកសំណើមកប្រធានគណៈកម្មការអន្តរក្រសួងពិនិត្យសម្រេច។ ក្នុងករណីអតីតយុទ្ធជន ឬគ្រួសារ បានមកបង្ហាញមុខតវ៉ា

ក្រុមការងារថ្នាក់រាជធានី ខេត្ត ត្រូវចុះត្រួតពិនិត្យឡើងវិញ បើជាអតីតយុទ្ធជន ឬគ្រួសារពិតប្រាកដ ត្រូវលើកសំណើសុំមកប្រធានគណៈកម្មការអន្តរក្រសួង សម្រេចទទួលស្គាល់ និងផ្តល់ប្រាក់ឧបត្ថម្ភជូន ។

៤-ត្រូវធ្វើសេចក្តីជូនដំណឹង ដល់អតីតយុទ្ធជនគ្រប់ប្រភេទ និងគ្រួសារ ក្នុងរយៈពេល១៥ថ្ងៃ មុនកាលកំណត់ត្រួតពិនិត្យផ្ទៀងផ្ទាត់ និងបើកផ្តល់ប្រាក់ឧបត្ថម្ភប្រចាំខែ ។

៥-ត្រូវមានវិធានការហ្មឺងម៉ាត់ ចំពោះអ្នកក្លែងបន្លំលិខិត ឯកសារអតីតយុទ្ធជន និងគ្រួសារ និងអ្នកនៅពីក្រោយអំពើក្លែងបន្លំ។

៦-ក្រសួងពាក់ព័ន្ធទាំងអស់ ចាត់វិធានការហ្មឺងម៉ាត់ចំពោះមន្ត្រីក្រោមឱវាទ ដែលពាក់ព័ន្ធការប្រមូលទិញ ការកេងប្រវ័ញ្ចប្រាក់របបគោលនយោបាយ របស់អតីតយុទ្ធជន និងគ្រួសារ ។

៧-ក្រសួងពាក់ព័ន្ធគាំទ្រ និងសហការជាមួយសមាគមអតីតយុទ្ធជនកម្ពុជា ក្រោមការដឹកនាំ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ក្នុងសកម្មភាពបេឡាឥណទាន ចលនាពាល្ល ដើម្បីជួយលើកកម្ពស់ជីវភាពអតីតយុទ្ធជន និងគ្រួសារ ។

IV-ក្រសួងការពារជាតិ ក្រសួងមហាផ្ទៃ និងក្រសួងស្ថាប័នពាក់ព័ន្ធ នៅរៀងរាល់ដើមឆ្នាំនៃឆ្នាំបន្ទាប់ ត្រូវបញ្ជូនបញ្ជីឈ្មោះជនពិការ និវត្តជន ជនបាត់បង់សមត្ថភាពការងារ ជនពលី ជនមរណៈ និងគ្រួសារ ដែលត្រូវផ្ទេរនោះ មកក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីបូកសរុបធ្វើគម្រោងថវិកានេះ សុំទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យបានមុនខែកក្កដា នៃឆ្នាំ ជាមូលដ្ឋានសម្រាប់គិតបញ្ចូលក្នុងកញ្ចប់ចំណាយថវិកាប្រចាំឆ្នាំ ។

V-សារាចរណែនាំអន្តរក្រសួងលេខ ០០២ សអយ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៧ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងការពារជាតិ ក្រសួងមហាផ្ទៃ ស្តីពីការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ មុខសញ្ញាអតីតយុទ្ធជនគ្រប់ប្រភេទ និងគ្រួសារ ត្រូវទុកជានិរាករណ៍ ។

VI-សារាចរណែនាំអន្តរក្រសួងនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។៚.

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ២៨ ខែ ៥ ឆ្នាំ២០១០

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

អ៊ិត-សំហេង

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ស ខេង

រដ្ឋមន្ត្រីក្រសួងការពារជាតិ

ទាយឧត្តមសេនីយ៍.ទៀ-បាញ់

**ចម្លងជូន**
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
<u>ដើម្បីជូនជ្រាប</u>
-គ្រប់អង្គភាពជំនាញចំណុះក្រសួង :
-ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងការពារជាតិ
-ក្រសួងមហាផ្ទៃ
-គ្រប់សាលារាជធានី ខេត្ត
<u>ដើម្បីអនុវត្ត</u>
-ឯកសារ-កាលប្បវត្តិ